

# ព្រះរាជកុមារ និងស្ដេចខ្លា


Wulan Mulya Pratiwi

Evi Shelvia



Let's Read

The Asia Foundation



ព្រះរាជកុមារស្រែក «ខ្ញុំចង់បានបាល់ធំជាងនេះ» ។ «មើលចំនួនលេខនេះទៅ! យើងត្រូវការស្លឹកឈើរាប់ពាន់... រាប់លាន...គឺច្រើនទៀត ដើម្បីយកមកធ្វើបាល់!»

អាមាត្រម្នាក់រៀបរាប់ប្រាប់ «ស្លឹកឈើទាំងអស់នេះចាស់ខ្លាំងណាស់ ក្រាបទូល។ ហើយវាស្រួយឆាប់បាក់ទៀត។ យើងមិនអាចយកមកធ្វើបាល់បានទេ»។

”ឆាប់ទៅរកពីក្នុងព្រៃភ្លាម!” ព្រះរាជកុមារបញ្ជាអាមាត្រទាំងអស់។

«ស្ដេចខ្លា អ៊ីនយ៉ា រស់នៅក្នុងព្រៃនេះ...»
ក្រុមអាមាត្រនិយាយ ហើយមើលមុខគ្នាទៅវិញទៅមក។
ពួកគេខ្លាចមែនទែន។



ព្រះរាជកុមារទើសចិត្តពេក «បានហើយ ខ្ញុំនឹងទៅរក ដោយខ្លួនឯង។ ខ្ញុំមិនខ្លាចទេ»

ព្រះរាជកុមារសម្លឹងរកមើលស្លឹកឈើណាដែលល្អជាងគេ។ ទ្រង់ប្រហែលអាចប្រទះដើមឈើដែលទ្រង់កំពុងរក។

ឬប្រហែលមាននៅទីនោះខ្លះទេដឹង ប៉ុន្តែរំពេចនោះ...



ងឹល! សំឡេងគ្រហឹមមួយលាន់ឡើង។



អូ មិនកើតទេ!

អាមាត្រទាំងអស់ស្រែក «នោះគឺអ៊ីនយ៉ា ស្តេចខ្លាព្រៃ»

ក្រុមអាមាត្ររត់គេចខ្លួនយ៉ាងលឿន។



ព្រះរាជកុមាររត់តាមមិនទាន់ ក៏បែកពីសេនាអាមាត្រអស់។
ទ្រង់គិតតែពីរត់ ចូលព្រៃកាន់តែជ្រៅទៅៗដោយមិនដឹងខ្លួន។

តើទ្រង់គួរធ្វើយ៉ាងណាពេលនេះ?

ទ្រង់រត់ទៅខាងណា ក៏ជួបខ្លាដែរ!



ទីបំផុត ខ្លាក៏ដើរចេញបាត់ទៅ។

ជារឿងល្អសម្រាប់ទ្រង់។ នេះជាឱកាសដើម្បីគេចខ្លួន។

ប៉ុន្តែ ទ្រង់មិនដឹងថាត្រូវទៅតាមផ្លូវណា។



អូ អត់ទេ!

ជួបខ្លាទៀតហើយ!



អូ ឈប់សិន។ លើកនេះដូចជាមានអ្វីខុសប្លែក។

សត្វខ្លាហាក់ដូចជាឈរបាំងតែមួយផ្លូវទេ។

តើសត្វខ្លាកំពុងព្យាយាមប្រាប់ផ្លូវដល់ព្រះរាជកុមារ មែនទេ?



«ងឹល...!» សំឡេងគ្រហឹម។

ខ្លានេះធ្វើអ្វីប្លែកៗ។

ប្រហែលជាខ្លាកំពុងព្យាយាមជួយព្រះរាជបុត្រ។



អាំ... សម្បកទុរេន! សម្បកទាំងនេះដាក់ពង្រាយជាជួរ។ តើនេះគឺជាតម្រុយសម្រាប់ព្រះរាជកុមារមែនទេ?

ពេលនេះ ព្រះរាជកុមារពិតជាភ័យណាស់ ប៉ុន្តែទ្រង់នៅតែដើរតាមសម្បកផ្លែឈើពង្រាយលើដីនោះ។ ទ្រង់ដើរមួយៗ យឺតៗ។



ឈប់សិន! សត្វខ្លាពិតជាកំពុងព្យាយាមជួយព្រះរាជកុមារពិតមែនទេតើ។

រាល់លើកដែលព្រះរាជកុមារវង្វេងដាន គឺសត្វខ្លាតែងតែផ្តល់តម្រុយដល់ទ្រង់ជានិច្ច។



ព្រះរាជកុមារធ្វើបានហើយ! ទីបំផុតទ្រង់មកដល់ភូមិអ្នកស្រុកហើយ។

ភ្លាមនោះ «ងឹល...!» សំឡេងខ្លាគ្រហឹមម្តងទៀត។

លើកនេះ ស្តាប់ទៅដូចជាសំឡេងគ្រហឹមឈឺ។



សត្វខ្លាជាប់អង្គប់!



សត្វខ្លាបានជួយព្រះរាជកុមារ។

ដូច្នេះ លើកនេះដល់វេនព្រះរាជកុមារសងគុណសត្វខ្លាវិញ។



ស្តេច និងសេនាអាមាត្រសម្រុកចូលទៅជួយទ្រង់ចេញពីស្តេចខ្លា។

«កុំធ្វើបាបគេអីព្រះបិតា! សត្វខ្លានេះបានជួយបុត្រ»



ស្តេចមានបន្ទូល «មនុស្ស និងសត្វខ្លាត្រូវតែគោរពគ្នា។ សត្វខ្លា បានសង្គ្រោះបុត្រយើង។ ដូច្នេះពីពេលនេះទៅ យើងមិនធ្វើបាប សត្វខ្លា ហើយខ្លាក៏មិនធ្វើបាបយើងដែរ។»

©2019, The Asia Foundation.

សៀវភៅនេះត្រូវបានបង្កើតឡើង តាមរយៈសិក្ខាសាលាសម្រាប់បង្កើតសៀវភៅជាភាសាក្នុងស្រុក ដែលបានសហការគ្នារវាងLitara Foundation រួមជាមួយ The Asia Foundation និង ISI Padang Panjang នៅភាគខាងលិចស៊ូម៉ាត្រា។ សិក្ខាសាលានិងការអភិវឌ្ឍវិជ្ជាជីវៈ រួមជាមួយនឹងការកែសម្រួល និងរចនាសៀវភៅនេះ ត្រូវបានធ្វើឡើងដោយ Litara Foundation ។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*Pangeran jo Inyiak (The Prince and Inyiak the Tiger)*, Author: Wulan Mulya Pratiwi. Illustrator: Evi Shelvia. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc/4.0/